**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤ ស.សរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈបញ្ជាការ ការពារសន្តិសុខគោលដៅ ទីស្តីការគណៈរដ្ឋមន្ត្រី និងទីស្តីការនាយករដ្ឋមន្ត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ៧៤ សសរ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈបញ្ជាការ ការពារសន្តិសុខគោលដៅទីស្តីការគណៈរដ្ឋមន្ត្រី និងទីស្តីការនាយករដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ ៖** ត្រូវបានកែសម្រួលសមាសភាពគណៈបញ្ជាការ ការពារសន្តិសុខគោលដៅទីស្តីការគណៈរដ្ឋមន្ត្រី និងទីស្តីការនាយករដ្ឋមន្ត្រី ដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរង នៃ ខ.ភ.ម និងជា មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស | ជាប្រធាន |
| ២- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ឃុ ស៊ុនឡុង** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | ជាអនុប្រធាន |

| | | | |
|---|---|---|---|
| ៣- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហ៊ុយ ពិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ប្រចាំការ<br>ដឹកនាំបញ្ជាបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន |
| ៤- | ឯកឧត្តម | **ឃឹម រុស្សីដា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន<br>គណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួល<br>ពិធីនិង កិច្ចប្រជុំនានានៅវិមានសន្តិភាព<br>ជាអនុប្រធាន |
| ៥- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ជួន សុវណ្ណ** | អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ និងជា<br>ស្នងការស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ<br>ជាអនុប្រធាន |
| ៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **តាន់ បញ្ញាវុធ** | នាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតី<br>តេជោ នាយករដ្ឋមន្ត្រី ជាអនុប្រធាន |
| ៧- | ឯកឧត្តម | **មួន លឹមហេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី<br>ជាសមាជិកទទួលបន្ទុកការងារធានាផ្គត់ផ្គង់<br>និងហិរញ្ញវត្ថុ |
| ៨- | ឯកឧត្តម | **សេង ឡៀង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជា<br>នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ<br>នាយករដ្ឋមន្ត្រី ជាសមាជិកទទួលការងារសម្របសម្រួល<br>ទូទៅនិងផ្គត់ផ្គង់ |
| ៩- | ឯកឧត្តម | **ឃួង ស្រេង** | អភិបាលរាជធានីភ្នំពេញ ជាសមាជិក ទទួលបន្ទុក<br>ការងារក្តាប់ព័ត៌មានទូទៅ ទប់ស្កាត់ ដោះស្រាយរាល់<br>បាតុភាព និងរាល់ពាក្យបណ្តឹងផ្សេងៗ |
| ១០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហ៊ុន ម៉ាណែត** | មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ព ជើងគោក<br>នាយរងសេនាធិការចំរុះ និងជា មេបញ្ជាការបញ្ជា<br>ការដ្ឋានជាតិកំលាំងពិសេសប្រឆាំងភេរវកម្ម<br>ជាសមាជិក ទទួលផែនសន្តិសុខការពារកៀកសម្តេច<br>តេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងអន្តរាគមន៍<br>ពិសេស |
| ១១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចៅ តុល** | នាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតី<br>តេជោ នាយករដ្ឋមន្ត្រី នាយរងសេនាធិការចំរុះ និងជា<br>មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ១២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឡៀង សារុន** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស<br>ជាសមាជិកអចិន្ត្រៃយ៍ |
| ១៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចន្ទ ពិសេន** | មេបញ្ជាការរង បញ្ជាការដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃ<br>ប្រទេស ជាសមាជិកទទួលការងារអន្តរាគមន៍ |
| ១៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ព្រហ្ម ឌិន** | មេបញ្ជាការយោធភូមិភាគពិសេស<br>ជាសមាជិកទទួលការងារអន្តរាគមន៍ |
| ១៥- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **អ៊ុង សារិទ្ធ** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស<br>ជាសមាជិកទទួលផែនអន្តរាគមន៍ |

| | | | |
|---|---|---|---|
| ១៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **តោគ ចន្ថា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកអចិន្ត្រៃយ៍ទទួលបន្ទុកដឹកនាំបញ្ជាកម្លាំងការពារសន្តិសុខក្នុងបរិវេណទីស្តីការគណៈរដ្ឋមន្ត្រី និង ទីស្តីការនាយករដ្ឋមន្ត្រី |
| ១៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ ចារុណ្ណ** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកទទួលផែនសន្តិសុខផ្ទាល់ |
| ១៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ សុចណ្ណា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ១៩- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **រ័ត្ន ស្រ៊ាង** | មេបញ្ជាការ កងរាជអាវុធហត្ថរាជធានីភ្នំពេញ ជាសមាជិក |
| ២០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សួន ពិរុណា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឡេង ម៉ុនណា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ុន រ៉ា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ៃ សារឿន** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២៤- | ឧត្តមសេនីយ៍ទោ | **ឆឹម ស៊ីណារត្ន** | មេបញ្ជាការ កងអនុក្រុមលេខ៣១១ ជាសមាជិក |
| ២៥- | ឧត្តមសេនីយ៍ទោ | **ខ៊ាន់ សារឿន** | អនុប្រធាន នាយកដ្ឋាននគរបាលការពារ ជាសមាជិក |

**ប្រការ ២** ៖ គណៈបញ្ជាការនេះ មានភារកិច្ចដូចខាងក្រោម ៖

- ការពារសន្តិសុខ សុវត្ថិភាព ក្នុង និងជុំវិញអគារទីស្តីការគណៈរដ្ឋមន្ត្រី និងអគារទីស្តីការនាយករដ្ឋមន្ត្រី ២៤ម៉ោងលើ២៤ម៉ោង
- គ្រប់គ្រងកងកម្លាំងប្រដាប់អាវុធទាំងអស់ដែលមានភារកិច្ចទទួលខុសត្រូវការពារក្នុងអគារទីស្តីការគណៈរដ្ឋមន្ត្រី និងអគារទីស្តីការនាយករដ្ឋមន្ត្រី
- ពិនិត្យជាតិផ្ទុះ ជាតិពុល ព្រមទាំងឆែកឆេរពល់សម្ភារៈ មធ្យោបាយ និងសមាសភាពទាំងអស់ដែលចូលក្នុងបរិវេណអគារទីស្តីការគណៈរដ្ឋមន្ត្រី និងអគារទីស្តីការនាយករដ្ឋមន្ត្រី
- សហការជាមួយគណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួលពិធីនិងកិច្ចប្រជុំនានាក្នុងអគារសន្តិភាព
- សហការជាមួយសមត្ថកិច្ច អាជ្ញាធរដែនដីពាក់ព័ន្ធ តាមដានក្តាប់សភាពការណ៍ ព្រមទាំងទប់ស្កាត់ រាល់សកម្មភាពកូដកម្ម បាតុកម្ម និងការតវ៉ាផ្សេងៗ ដែលនាំអោយប៉ះពាល់ដល់ការរៀបចំពិធីក្នុងអគារទីស្តីការគណៈរដ្ឋមន្ត្រី និងអគារទីស្តីការនាយករដ្ឋមន្ត្រី
- ពិនិត្យរាល់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចសន្តិសុខ នៅក្នុង និងជុំវិញអគារទីស្តីការគណៈរដ្ឋមន្ត្រី និងអគារទីស្តីការនាយករដ្ឋមន្ត្រី ។

**ប្រការ ៣** ៖ គណៈបញ្ជាការ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** ៖ អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានគណៈបញ្ជាការ ។

**ប្រការ ៥ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសមាសភាពគណៈបញ្ជាការដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០១៧*

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល ៖*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ៥*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*